**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ ០១៤/២៥ ប្រក... អររ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃការអញ្ជើញចូលរួមសន្និសីទរបស់អង្គការសហប្រជាជាតិ ស្តីពីមហាសមុទ្រ លើកទី៣ របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងនីស សាធារណរដ្ឋបារាំង

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាល អញ្ជើញនិវត្តន៍មកដល់រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ នេះ បន្ទាប់ពីបញ្ចប់ការអញ្ជើញចូលរួមសន្និសីទរបស់អង្គការសហប្រជាជាតិ ស្តីពីមហាសមុទ្រ លើកទី៣ ក្រោមប្រធានបទ «ការពន្លឿនសកម្មភាព និងការកៀរគរគ្រប់តួអង្គដើម្បីរក្សានិងប្រើប្រាស់មហាសមុទ្រប្រកបដោយចីរភាព» រយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី៩ ដល់ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥ នៅទីក្រុងនីស សាធារណរដ្ឋបារាំង។ ការអញ្ជើញចូលរួមសន្និសីទរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** គឺតបតាមការអញ្ជើញរបស់ **ឯកឧត្តម Emmanuel Macron** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង និង **ឯកឧត្តម António Guterres** អគ្គលេខាធិការអង្គការសហប្រជាជាតិ (អ.ស.ប.)។

**ក្នុងក្របខ័ណ្ឌសន្និសីទរបស់អង្គការសហប្រជាជាតិ ស្តីពីមហាសមុទ្រ លើកទី៣ (UNOC3)៖ សម្តេចធិបតី** បានអញ្ជើញចូលរួមក្នុងពិធីបើក និងថ្លែងសុន្ទរកថានៅក្នុងសន្និសីទនេះ ដោយបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជា ក្នុងការក្លាយជាភាគីនៃកិច្ចព្រមព្រៀងអនុសញ្ញាស្តីពីសម្បត្តិធម្មជាតិនៅក្រៅអធិបតេយ្យភាពជាតិ (BBNJ) ដែលត្រូវបានអនុម័តនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ហើយកម្ពុជានឹងបោះជំហានបន្ទាប់ក្នុងការបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួន ដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀង BBNJ នេះ។ **សម្តេចធិបតី** ក៏បានលើកឡើងពីការប្តេជ្ញាពង្រឹងសមត្ថភាពជាតិរបស់ខ្លួនក្នុងការការពារសមុទ្រ តាមរយៈការពង្រីកតំបន់ការពារដែនសមុទ្រ ពង្រឹងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងជលផលប្រកបដោយនិរន្តរភាព និងពង្រឹងគំនិតផ្តួចផ្តើមថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការបំពុលសមុទ្រ។ ក្នុងន័យនេះ **សម្តេចធិបតី** បានអំពាវនាវដល់សហគមន៍អន្តរជាតិផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសំខាន់ៗដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកសាងសមត្ថភាពសម្រាប់ការអភិរក្សសមុទ្រ និងការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពនឹងរួមបញ្ចូលទាំងការធានានូវលទ្ធភាពទទួលបានវិទ្យាសាស្ត្រ ចំណេះដឹង បច្ចេកវិទ្យា និងការផ្តល់មូលនិធិ ជាពិសេសសម្រាប់ការស្រាវជ្រាវសមុទ្រ ការត្រួតពិនិត្យ និងការបង្កើតការអនុវត្តគ្រប់គ្រងជលផលប្រកបដោយនិរន្តរភាព។

**ក្នុងក្របខ័ណ្ឌនយោបាយ និងការទូត៖ សម្តេចធិបតី** បានជួបពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តម Emmanuel Macron** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង **ឯកឧត្តម Emomali Rahmon** ប្រធានាធិបតី នៃសាធារណរដ្ឋតាជីគីស្ថាន និង **ឯកឧត្តម Robert Breugre Mambe** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋកូតឌីវ័រ និងជួបសំណេះសំណាលជាមួយរដ្ឋទាយាទនៃប្រទេសន័រវែស ផងដែរ។

**ជំនួបពិភាក្សាទ្វេភាគីជាមួយប្រធានាធិបតីបារាំង៖** ក្នុងជំនួបនោះ **ឯកឧត្តមប្រធានាធិបតី** បានគូសបញ្ជាក់ថា រដ្ឋាភិបាលបារាំងនឹងផ្តល់ការគាំទ្រដល់កម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ឆ្នាំ២០២៦ ឱ្យបានជោគជ័យ ហើយ **ឯកឧត្តមប្រធានាធិបតី** នឹងអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នាឆ្នាំ២០២៦ ខាងមុខនេះ។ **ឯកឧត្តមប្រធានាធិបតី** នឹងបញ្ជូនគណៈប្រតិភូដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីលើកកម្ពស់ភាពជាដៃគូពាណិជ្ជកម្ម និងសេដ្ឋកិច្ចបន្ថែមទៀត។ **សម្តេចធិបតី** បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមប្រធានាធិបតីបារាំង ដែលផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់កម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ឆ្នាំ២០២៦។ **សម្តេចធិបតី** បានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជានិងបារាំង ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរវាងប្រទេសទាំងពីរ ក្នុងការរៀបចំឯកសារផែនទីបង្ហាញផ្លូវដើម្បីឈានដល់ការដំឡើងកម្រិតនៃទំនាក់ទំនងកម្ពុជា-បារាំង ជា «ដៃគូយុទ្ធសាស្ត្រ» ហើយរដ្ឋាភិបាលបារាំងក៏នឹងបន្តគាំទ្រវិស័យការពារជាតិនៅកម្ពុជា ផងដែរ។ **សម្តេចធិបតី** និង **ឯកឧត្តមប្រធានាធិបតី** ក៏បានពិភាក្សាអំពីការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសក្តានុពលមួយចំនួនរវាងប្រទេសទាំងពីររួមមានវិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ច ការពារជាតិនិងសន្តិសុខ ថាមពល និងវប្បធម៌ ជាដើម។

**ជំនួបពិភាក្សាទ្វេភាគីជាមួយប្រធានាធិបតីតាជីគីស្ថាន៖ ឯកឧត្តមប្រធានាធិបតី** បានគូសបញ្ជាក់ថា ជំនួបពិភាក្សាការងារទ្វេភាគីនេះ នឹងជួយពង្រឹងនិងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍ជូនដល់ប្រជាជន និងប្រទេសទាំងពីរ។ **ឯកឧត្តមប្រធានាធិបតី** បានលើកឡើងថា ប្រទេសតាជីគីស្ថានមានឧត្តមភាពខាងវិស័យថាមពល និងថាមពលស្អាត ចំណែកកម្ពុជាជាប្រទេសមានសក្តានុពលផ្នែកកសិកម្ម ដោយអាចធានានូវការផ្គត់ផ្គង់ស្បៀងក្នុងស្រុក និងមានអតិរេកស្បៀងសម្រាប់បម្រើដល់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ជាមួយគ្នានេះ **សម្តេចធិបតី** បានថ្លែងថា ជំនួបទ្វេភាគីនេះ ជាឱកាសសម្រាប់ការស្វែងរកកាលានុវត្តភាពនៃកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗរវាងប្រទេសទាំងពីរ។ **ថ្នាក់ដឹកនាំទាំងពីរ** គ្រោងនឹងអញ្ជើញបំពេញទស្សនកិច្ចផ្លូវការទៅវិញទៅមកនាពេលវេលាសមស្របខាងមុខ ព្រមទាំងបានប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ ដើម្បីបន្តផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធ។

**ជំនួបពិភាក្សាទ្វេភាគីជាមួយនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋកូតឌីវ័រ៖ សម្តេចធិបតី** បានគូសបញ្ជាក់ថា ប្រទេសទាំងពីរមានភាពប្រហាក់ប្រហែលគ្នាមួយចំនួន ជាពិសេសនៅក្នុងមូលដ្ឋានសេដ្ឋកិច្ច។ បន្ថែមលើនេះ **សម្តេចធិបតី** បានអញ្ជើញ **ឯកឧត្តមនាយករដ្ឋមន្ត្រី** មកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងពេលវេលាសមស្របណាមួយ និងពិនិត្យលទ្ធភាពចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ឆ្នាំ២០២៦ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៅខេត្តសៀមរាប។ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានកោតសរសើរភាពជាអ្នកដឹកនាំប្រកបដោយសមត្ថភាពរបស់ **សម្តេចធិបតី** ដែលបន្តរក្សាបាននូវសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។ ជាមួយគ្នានោះ **ឯកឧត្តម**

**នាយករដ្ឋមន្ត្រី** សង្ឃឹមថា នឹងមានឱកាសបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា និងចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ នៅឆ្នាំ២០២៦ ដែលជាកាលានុវត្តភាពនៃការបន្តកិច្ចពិភាក្សាទ្វេភាគី សំដៅពង្រឹងនិងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានសន្យាថា នឹងចាត់រដ្ឋមន្ត្រីឧស្សាហកម្ម មកបំពេញទស្សនកិច្ចការងារនៅកម្ពុជា ដើម្បីពិនិត្យនិងសិក្សាលទ្ធភាពពង្រីក ការផ្សារភ្ជាប់កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍមូលដ្ឋានផលិតកម្មជាមួយប្រទេសកម្ពុជា។ **នាយករដ្ឋមន្ត្រីទាំងពីរ** ក៏បានឯកភាពក្នុងការបន្តពិនិត្យលទ្ធភាពពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យផ្សេងៗ ឱ្យកាន់តែខ្លាំងក្លា បន្ថែមទៀត ដើម្បីជាផ្លែផ្កានិងឧត្តមប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

ក្នុងឱកាសនៃការអញ្ជើញចូលរួមក្នុងសន្និសីទនេះដែរ **សម្តេចធិបតី** បានឆ្លៀតពេលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយ **ឯកឧត្តម António Costa** ប្រធានក្រុមប្រឹក្សាអឺរ៉ុប **លោកជំទាវ Ursula von der Leyen** ប្រធានគណៈកម្មការអឺរ៉ុប **ឯកឧត្តម Christian Estrosi** អភិបាលក្រុងនីស **ព្រះអង្គម្ចាស់ Haakon** រជ្ជទាយាទ នៃប្រទេសន័រវេស **ឯកឧត្តម Sepp Schellhorn** រដ្ឋលេខាធិការក្រសួងសហព័ន្ធសម្រាប់អឺរ៉ុប និងកិច្ចការអន្តរជាតិ នៃប្រទេសអូទ្រីស **លោកជំទាវ Annelies Jan Louisa Verlinden** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រ បែលហ្ស៊ិក ក្នុងគោលដៅស្វែងរកកាលានុវត្តភាពនៃកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ និងដើម្បីពង្រឹងនិងពង្រីក ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀត សម្រាប់ជាឧត្តមប្រយោជន៍ជូនប្រទេសជាតិ និងប្រជាជនកម្ពុជា។

សូមបញ្ជាក់ថា នេះជាដំណើរបំពេញបេសកកម្មការងារនៅក្រៅប្រទេសថ្មីមួយទៀត របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពី **សម្តេច** បានអញ្ជើញបំពេញទស្សនកិច្ច ប្រកបដោយជោគជ័យដ៏ធំធេងក្នុងតំបន់អាស៊ី អាម៉េរិក អឺរ៉ុប និងមជ្ឈិមបូព៌ា នាពេលកន្លងមក។ នេះក៏ជាសមិទ្ធផល ការងារការទូតដ៏ធំមួយទៀត សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ទៅដល់ទីកន្លែងណា ក៏ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** តែងតែស្រវាស្រទេញបង្កើនទំនាក់ទំនងការទូតក៏ដូចជាពាណិជ្ជកម្ម ដើម្បីនាំមកនូវផលប្រយោជន៍ ជូនប្រទេសជាតិនិងប្រជាពលរដ្ឋមិនដែលខានឡើយ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥